ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍

**BUDDHISM FOR DEVELOPMENT**

**KAMPONG THOM BRANCH OFFICE**

# របាយការណ៍សិក្ខាសាលា
## ប្រតិបត្តិករឥណទានជនបទ ពជអ និងការងារគ្រប់គ្រងឥណទាន
## តាមរយៈការជ្រើសរើសនាយកប្រតិបត្តិ សអក
## សាលប្រជុំមន្ទីរកសិកម្ម ខេត្តកំពង់ធំ ថ្ងៃទី ៥ កុម្ភៈ ២០១៦

--------------



នៅថ្ងៃទី ៥ កុម្ភៈ ២០១៦ នៅសាលប្រជុំមន្ទីរកសិកម្មខេត្តកំពង់ធំ មានរៀបចំសិក្ខាសាលាមួយ ស្តីពី *"ប្រតិបត្តិករឥណទានជនបទ ពជអ និងការងារគ្រប់គ្រងឥណទាន តាមរយៈការជ្រើសរើសនាយកប្រតិបត្តិ សអក"* ដែលរៀបចំដោយអង្គការពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍សាខាខេត្តកំពង់ធំ ក្រោមជួយឧបត្ថម្ភពីមូលនិធិសហពន្ធ័សហករណ៍រាយហ្វៃសិន, អាល្លឺម៉ង់ (DGRV) ក្រោមអធិបតីភាព លោក កាន់ សាឡុន អនុប្រធានមន្ទីរកសិកម្មខេត្តកំពង់ធំ លោក ភាជ ផល្លុន តំណាងលោកធម្មបណ្ឌិត ហេង មណីចិន្តា នាយកពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ និងជាចៅកូវកម្មវិធី សហករណ៍ លោក សុខ សុផល ប្រធានសាខាពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍សាខាកំពង់ធំ និងដោយមានការចូលរួមពីក្រុមប្រឹក្សាសហគមន៍ទាំង ២០ ដែលគាំទ្រដោយ ពជអ នៅក្នុងខេត្តកំពង់ធំ។

គោលបំណងនៃអង្គសិក្ខាសាលាគឺ៖



- ដើម្បីបង្ហាញអំពីផែនការឆ្នាំ២០១៦ ដល់សហគមន៍កសិកម្ម ដែលគាំទ្រដោយ **ពជអ**
- ដើម្បីផ្សព្វផ្សាយអំពី សេវាឥណទានរបស់ **ពជអ** ដល់សហគមន៍កសិកម្ម
- ដើម្បីពង្រឹងសហគមន៍តាមច្បាប់ ស្តីពីសហគមន៍កសិកម្ម ឆ្នាំ២០១៣

ខ្លឹមសារ និងលទ្ធផល

អង្គពិធីសិក្ខាសាលាបានលើកយកមាតិកាចំនួន ៥ មកបង្ហាញ៖

1. ***សាវតា /ប្រវត្តិគំរោងកម្មវិធីសហករណ៍ ពជអ***

   លោកសុខ សុផល ក៏បានជំរាបជូនជូនអង្គពិធីថា កម្មវិធីសហករណ៍ ជាកម្មវិធីមួយក្នុងចំណោមគំរោងកម្មវិធីផ្សេងៗទៀត ដែលអនុវត្តន៍ដោយអង្គការពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ (ពជអ) ហើយគំរោងនេះស្ថិតនៅក្នុងផែនការយុទ្ធសាស្រ្តទី១ នៃផែនការយុទ្ធសាស្រ្តទាំង ៥ របស់ **ពជអ** ។ កម្មវិធីនេះ បានចាប់ផ្តើមតាំងពីចុងឆ្នាំ២០០៣ ហើយបច្ចុប្បន្នបានពង្រីកខេត្តទាំង ៧ ដែលជាខេត្តគោលដៅរបស់ពជអ ដោយមានការឧត្ថម្ភគាំទ្រពីមូលនិធីសហករណ៍អាល្លឺម៉ង់ និងសហព័ន្ធរាយហ្វៃសិន (DGRV)។ គោលបំណងនៃការបង្កើតគំរោងកម្មវិធីសហករណ៍ គឺដើម្បីធ្វើឱ្យប្រសើរឡើងនូវខ្នាតគំរូសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ និងបង្កើតឱ្យមានសហគ្រាសជំនួញខ្នាតតូចដល់ក្រុមជួយខ្លួនឯង ដើម្បីឈានទៅដល់ការបង្កើតរចនាសម្ព័ន្ធសហករណ៍ នៅតំបន់ជនបទក្នុងភូមិភាគពាយ័ព្យ នៃប្រទេសកម្ពុជា។ ហើយការគាំទ្ររបស់ពជអ ទៅលើសហគមន៍ គឺ៖

   1. ផ្តល់វគ្គបណ្តុះបណ្តាលដែលចាំបាច់ដល់ ថ្នាក់ដឹកនាំ និងសមាជិកសហករណ៍
   2. ផ្តល់ប្រឹក្សាយោបល់ដល់សហករណ៍ ជាពិសេស ការដឹកនាំ-គ្រប់គ្រង និងការធ្វើជំនួញ

ផ្លូវលេខ ៣ ផ្ទះលេខ ១៣៨ ក្រុមទី ១៣ ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ

Tel: 012 553 123 / 071 956 3434 / 097 600 3968 / 096 557 4425 Email: bfdktm@bfdkhmer.org

Webpage: www.bfdkhmer.org

3. ផ្តល់បច្ចេកទេសអំពីសេវាសន្សំប្រាក់-ឥណទាន និងកសិកម្មគ្រួសារ
4. ផ្លាស់ប្តូរបទពិសោធន៍នានា តាមរយៈសិក្ខាសាលា ការប្រជុំ និងទស្សនៈកិច្ចសិក្សា
5. ផ្តល់សេវា និងឥណទានខ្នាតតូច សំរាប់ដំណើរការកម្មវត្ថុសហករណ៍ ជាពិសេសការទិញ-លក់ផលិតផលកសិកម្មរួមគ្នា ។

2. *សារៈសំខាន់នៃនាយកប្រតិបត្តិរបស់សហគមន៍កសិកម្ម*

លោក ភាជ ផល្លួន បានបង្ហាញនូវខ្លឹមសារនៃមាត្រា ៤៨ នៃច្បាប់សហគមន៍កសិកម្ម ដែលបង្ហាញថា ក្រុមប្រឹក្សាភិបាលអាចជ្រើសរើសនាយកប្រតិបត្តិជាប់កិច្ចសន្យាម្នាក់បាន និងមាត្រា ៤៩ ដែលបង្ហាញថា ក្រុមប្រឹក្សាភិបាលអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាតាមការចាំបាច់ ដើម្បីបម្រើការងារក្នុងប្រតិបត្តិការ ព្រមជាមួយនឹងការបង្ហាញជូនពីសារៈសំខាន់របស់នាយកប្រតិបត្តិ ក្នុងការប្រតិបត្តិការមុខរបរសំរាប់សហគមន៍។ លោកក៏បានបង្ហាញជូនពីនិតិវិធី និងលក្ខខណ្ឌសំរាប់ការជ្រើសរើសនាយកប្រតិបត្តិនេះផងដែរ ព្រមជាមួយនេះ លោកក៏បានបង្ហាញពីជំហររបស់ពដអ ដែលចង់ឲ្យសហគមន៍ទាំងអស់ មាននាយកប្រតិបត្តិ ដោយបានលើបង្ហាញនូវលិខិតជូនដំណឹងរបស់ពដអ ចុះថ្ងៃទី ៣០ ធ្នូ ២០១៥ ក្នុងការកាត់បន្ថយនូវការប្រាក់ ដើម្បីជាការចូលរួមចំណែកជាមួយសហគមន៍ ក្នុងការផ្តល់ប្រាក់បៀវត្សរ៍ ដល់នាយកប្រតិបត្តិ។

3. *ផែនការកម្មវិធីសហករណ៍ សំរាប់ឆ្នាំ ២០១៦ របស់ពដអ*

លោកសុខ សុផល ក៏បានបង្ហាញពីផែនការបន្ត ជាពិសេសទាក់ទងនឹងសកម្មភាពបណ្តុះបណ្តាលមួយចំនួនដែលនឹងត្រូវអនុវត្តក្នុងឆ្នាំ ២០១៦នេះ ដោយធ្វើការពិភាក្សាទៅលើកាលបរិច្ឆេទដែលនឹងត្រូវធ្វើ ហើយអង្គពិធីទាំងមូលក៏បានសំរេចយកទៅតាមផែនការ។

4. *គោលការណ៍ និងសេវាកម្មឥណទានរបស់ ពដអ*

ទាក់ទងគោលការណ៍ និងសេវាឥណទានរបស់អង្គការ ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ លោកផល្លួន ក៏បានធ្វើការពន្យល់យ៉ាងក្បោះក្បាយពីនិតិវិធីរបស់ ពដអ ក្នុងការផ្តល់សេវាឥណទានទៅដល់សហគមន៍ទាំងកំចីសហគមន៍ និងកំចីទោលរបស់សមាជិកសហគមន៍។ លោកក៏បានលើកឡើងផងដែរពីការយកចិត្តទុកដាក់របស់ ពដអ ចំពោះសហគមន៍ជាពិសេសសេចក្តីសំរេចរបស់លោកនាយកនៅក្នុងលិខិតជូនដំណឹង ចុះថ្ងៃទី ៣០ ធ្នូ ២០១៥ ដែលជាការលើកទឹកចិត្តឲ្យសហគមន៍ជ្រើសរើសយកនាយកប្រតិបត្តិ ។

5. *ការបែងចែកប្រាក់ចំណេញ ដែលបានមកពីការប្រាក់ និងប្រាក់ភាគលាភរបស់សហគមន៍កសិកម្ម*

លោក កាន់ សាឡន ក៏បានធ្វើបទបង្ហាញមួយទាក់ទងនឹងការបែងចែកប្រាក់ចំណេញ ដោយលោកបានលើកយកមាត្រា៥៧, ៥៨ និង ៥៩ នៃច្បាប់គ្រប់គ្រងសហគមន៍មកបង្ហាញ។

អង្គពិធីទាំងមូលបានបញ្ចប់ទៅដោយជោគជ័យ ក្នុងបរិយាកាសរីករាយ និងស្និតស្នាល។

កំពង់ធំ ថ្ងៃទី ៦ កុម្ភៈ ២០១៦
កត់ត្រាដោយ

សុខ សុផល